# ទីពឹងចុងក្រោយ

ក្នុងសម័យកាលដែលព្រះដ៏មានព្រះភាគទ្រង់រលត់ខ័ន្ធចូលកាន់បរិនិព្វានថ្មីៗ ព្រះមហាកច្ចាយនៈអាស្រ័យនៅក្នុងព្រៃមួយកន្លែងក្នុងបច្ចន្តជនបទ សម័យនោះព្រះបាទអស្សករាជសោយរាជ្យសម្បត្តិក្នុងបោតលិនគរ ដែនអស្សកៈ ។ ព្រះរាជកុមារព្រះនាមថា សុជាត ជាព្រះរាជឱរសនៃព្រះអគ្គមហេសីរបស់ព្រះបាទអស្សករាជ មានព្រះជន្មាយុ ១៦ ព្រះវស្សា ចាកចេញពីនគរព្រោះតែការដណ្តើមរាជសម្បត្តិជាមួយព្រះមហេសីចុងរបស់បិតា ព្រះអង្គក៏ចូលព្រៃអាស្រ័យនៅជាមួយពពួកព្រានក្នុងព្រៃ ។

មានសេចក្តីដំណាលថា ព្រះរាជកុមារអង្គនោះ ធ្លាប់បួសជាភិក្ខុក្នុងសាសនាព្រះពុទ្ធព្រះនាមកស្សបៈ ទ្រទ្រង់ក្នុងគុណត្រឹមតែសីល បានស្លាប់ទៅដោយនៅជាបុថុជ្ជន ហើយក៏ទៅកើតក្នុងឋានសួគ៌ជាន់តាវត្តិង្ស ត្រាច់រង្គាត់ក្នុងសុគតិភពអស់រយៈពេលជាយូរ ។ លុះព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដឹង បាន ៣០ ព្រះវស្សា ក៏បានច្យុតចុះមកចាប់បដិសន្ធិក្នុងផ្ទៃនៃព្រះអគ្គមហេសីរបស់ព្រះបាទអស្សកៈ ។

កាលដែលព្រះអគ្គមហេសីអស់ព្រះជន្មទៅ ព្រះបាទអស្សករាជក៏តែងតាំងព្រះមហេសីចុង ឱ្យឡើងជាអគ្គមហេសី ក្រោយមកព្រះនាងបានប្រសូតិព្រះឱរសមួយអង្គ ព្រះរាជាទ្រង់សព្វព្រះរាជហឫទ័យចំពោះព្រះឱរសនោះយ៉ាងខ្លាំងបានប្រទានពរអោយព្រះនាងទទួលយករបស់ដែលជាទីប្រាថ្នា ព្រះនាងទទួលទុក តែមិនទាន់សុំពរក្នុងពេលភ្លាមៗនោះទេ ។

លុះសុជាតកុមារមានព្រះជន្មវស្សាបាន១៦ព្រះវស្សា ព្រះនាងក៏សំអាងនូវពរដែលព្រះអង្គបានប្រទាន ក្រាបទូលសុំរាជសម្បត្តិអោយឱរសរបស់ខ្លួន ព្រះរាជាទ្រង់បដិសេធ ទោះជាព្រះទេវីសុំជាញឹកញាប់ក៏មិនអាចធ្វើអោយព្រះរាជាទន់ព្រះទ័យបាន ។

ថ្ងៃមួយ ព្រះទេវីក្រាបទូលព្រះរាជាថា បពិត្រព្រះទេវៈ បើព្រះអង្គនៅតែប្រកាន់ពាក្យសច្ចៈ សូមព្រះអង្គប្រទានរាជសម្បត្តិអោយបុត្ររបស់ខ្ញុំម្ចាស់ផងចុះ ។

ព្រះរាជាទ្រង់ខកព្រះទ័យយ៉ាងខ្លាំងដែលនាងនិយាយដូច្នេះ តែក៏ទ្រង់បដិសេធមិនបាន សុជាតកុមារបានដឹងក៏ទូលលាព្រះបិតាទៅនៅក្នុងព្រៃ ព្រះរាជាទ្រង់មិនយល់ព្រម តែព្រះរាជកុមារអះអាងថានឹងទៅ ព្រះរាជាក៏ទ្រង់អនុញ្ញាតទាំងទឹកព្រះនេត្រ ។

ព្រះរាជកុមារចូលព្រៃអាស្រ័យនៅជាមួយពួកព្រាន ថ្ងៃមួយទៅដេញម្រឹគ មានទេវបុត្រមួយអង្គធ្លាប់ជាសំលាញ់នឹងគ្នាកាលគេនៅបួសជាសមណៈ បានក្រឡាខ្លួនជាម្រឹគ មកបញ្ឆោតគេដោយ បំណងល្អរត់ទៅក្បែរសំណាក់ព្រះមហាកច្ចាយនៈហើយក៏បាត់ទៅ ។ ព្រះរាជកុមាររត់ដេញចាប់ម្រឹគ នោះរហូតដល់ទីស្នាក់អាស្រ័យរបស់ព្រះមហាកច្ចាយនៈក៏មិនឃើញម្រឹគ ឃើញតែព្រះមហាកច្ចាយនៈ គង់នៅក្រៅបណ្ណសាលា ទើបកាន់ធ្នូឈរនៅក្បែរព្រះមហាកច្ចាយនៈ ។

ព្រះមហាកច្ចាយនៈដឹងហេតុរបស់គេទាំងអស់ តែព្រះអង្គធ្វើជាមិនដឹង ដើម្បីអនុគ្រោះដល់គេទើបសួរថា អ្នកស្ពាយធ្នូដែលធ្វើដោយឈើខ្លឹមដ៏រឹងមាំ តើអ្នកជានរណាទៅហ្ន៎?

បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំព្រះករុណាឈ្មោះសុជាត ជាឱរសរបស់ព្រះបាទអស្សកៈ ត្រាច់ចរវង្កាត់ក្នុងព្រៃធំដើម្បីស្វែងរកពួកម្រឹគតែមិនឃើញម្រឹគឃើញតែលោកម្ចាស់ ទើបបានឈរនៅទីនេះ ។

ព្រះមហាកច្ចាយនៈទូលថា អ្នកដ៏មានបុណ្យខ្ពង់ខ្ពស់ ការមកពីទីឆ្ងាយរបស់អ្នកឈ្មោះថាមកល្អហើយ ចូរដងទឹកលាងជើងរបស់អ្នក ហើយអញ្ជើញផឹកទឹកដ៏ថ្លាត្រជាក់ ហើយអង្គុយលើកម្រាលដែលក្រាលទុកស្រេចនោះចុះ ។

ព្រះរាជកុមារត្រាស់ថា បពិត្រព្រះមហាមុនី វាចារបស់ព្រះអង្គពីរោះចាប់ចិត្តខ្លាំងណាស់ជាវាចាដែលមានតែប្រយោជន៍ ព្រះអង្គមកគង់នៅក្នុងព្រៃ តើរីករាយនឹងអ្វី មេត្តាប្រាប់ខ្ញុំព្រះករុណាផង ។

ព្រះមហាកច្ចាយនៈទូលថា ម្នាលព្រះរាជកុមារ អាត្មាចូលចិត្តការមិនបៀតបៀនសត្វទាំងពួងការមិនលួចឆក់ទ្រព្យគេ ការមិនប្រព្រឹត្តកន្លងក្នុងកាម ការមិនសេពគ្រឿងស្រវឹង និងចូលចិត្តការមិន ធ្វើបាបការប្រព្រឹត្តស្ងប់ ភាពជាពហូសូត ភាពកតញ្ញូ ព្រោះធម៌ទាំងអស់នេះវិញ្ញូជនសរសើរ ។

ក្រោយមក ព្រះមហាកច្ចាយនៈបានប្រមើលមើលដោយអនាគតង្សញ្ញាណ ( ប្រាជ្ញាដឹងអនាគត) ឃើញអាយុរបស់ព្រះរាជកុមារសល់ត្រឹមតែប្រាំខែទៀតប៉ុណ្ណោះ ។ ដើម្បីអោយគេមានចិត្តតក់ស្លុតហើយតាំងនៅក្នុងសម្មាបដិបត្តិ ទើបទូលថា ម្នាលព្រះរាជកុមារ សេចក្តីស្លាប់របស់អ្នកខិតចូលមកកាន់តែជិតហើយ អ្នកនឹងធ្វើមរណកាលនៅអំឡុងប្រាំខែទៀត ចូរអ្នកជ្រាបហើយប្រញាប់រំដោះខ្លួនចេញ ។

ព្រះរាជកុមារសួរពីឧបាយដែលធ្វើអោយរួចផុតថា ខ្ញុំព្រះករុណាគប្បីទៅទីណា ធ្វើការងារអ្វីធ្វើកិច្ចអ្វីរបស់បុរស ឬគប្បីសិក្សាវិជ្ជាអ្វីទៅទើបមិនចាស់មិនស្លាប់ ?

ព្រះមហាកច្ចាយនៈទូលថា ម្នាលព្រះរាជកុមារ មិនមានទីកន្លែងណាដែលសត្វទៅហើយមិនចាស់មិនស្លាប់ទេ មិនមានការងារ កិច្ចរបស់បុរស ឬវិជ្ជាអ្វីដែលសត្វធ្វើឬរៀនសូត្រហើយមិនចាស់មិនស្លាប់នោះទេ ។

ជនអ្នកមានទ្រព្យច្រើន មានភោគសម្បត្តិច្រើន ជាក្សត្រគ្រប់គ្រងផែនដី មានទ្រព្យនិងស្រូវហូរហៀរ អ្នកទាំងអស់នោះនឹងមិនចាស់មិនស្លាប់ ក៏មិនមែន ។

លោកអ្នកដែលមានវិជ្ជាគុនបានសិក្សាហើយ អង់អាច ខ្លាំងពូកែ អាចប្រហារពួកសត្រូវបាន សូម្បីអស់លោកទាំងអស់នោះក៏ដល់នូវការអស់អាយុ នឹងស្ថិតនៅគង់វង្ស ដូចព្រះអាទិត្យព្រះច័ន្ទ្រ ក៏មិនមែន ។

ក្សត្រ ព្រាហ្មណ៏ វេស្សៈ សូទ្រ ចណ្ឌាល អ្នកកើបសំរាម និងជនជាតិដទៃៗទៀត សូម្បីពួកទាំងអស់នោះ នឹងមិនចាស់ មិនស្លាប់ក៏មិនមែន ។

លោកអ្នកដែលរៀនមន្តព្រហ្មចិន្តាដែលមានអង្គ៦ អ្នកដែលរៀនវិជ្ជាផ្សេងៗ សូម្បីគេទាំងអស់នោះ នឹងមិនចាស់មិនស្លាប់ ក៏មិនមែន។

ម្យ៉ាងទៀត ពួកឬស្សីអ្នកតាំងចិត្តស្ងប់ សង្រួមកាយ បំពេញតបៈ សូម្បីលោកទាំងនោះ ក៏ចាំបាច់ត្រូវបោះបង់រាងកាយទៅតាមកាលវេលា ។

ទោះជាព្រះអរហន្តទាំងឡាយដែលអប់រំចិត្តល្អហើយ ជាអ្នកចប់កិច្ចហើយ មិនមានកិលេស អស់បុណ្យនិងបាប ក៏ចាំបាច់ត្រូវតែលះបង់រាងកាយនេះទៅ ។

ព្រះរាជកុមារត្រាស់ថា បពិត្រព្រះមហាមុនី ខ្ញុំព្រះករុណាធូរស្រាលក្នុងចិត្តព្រោះវាចាដែលព្រះអង្គពោលល្អហើយ សូមព្រះអង្គធ្វើជាទីពឹងរបស់ខ្ញុំព្រះករុណាផង ។

អ្នកកុំដល់អាត្មាភាពជាទីពឹងអី ចូរដល់នូវព្រះពុទ្ធដែលជាព្រះមហាបុរសដែលអាត្មាយកជាទីពឹងថាជាទីពឹងចុះ ។

ព្រះរាជកុមារត្រាស់សួរថា ព្រះពុទ្ធជាម្ចាស់ដែលជាបរមគ្រូរបស់ព្រះអង្គពេលនេះប្រថាប់នៅទី ណា ខ្ញុំព្រះករុណានឹងទៅគាល់ព្រះសម្មាសម្ពុទ្ធអង្គនោះ ដែលរកបុគ្គលប្រៀបស្មើគ្មាន ។

ព្រះថេរៈតបថា ព្រះពុទ្ធបរមគ្រូទ្រង់ជាបុរសអាជានេយ្យ ប្រថាប់នៅទិសខាងកើត តែព្រះអង្គទ្រង់ចូលបរិនិព្វានហើយ ។

ព្រះរាជកុមារត្រាស់ថា បើព្រះពុទ្ធជាម្ចាស់ដែលជាបរមគ្រូរបស់ព្រះអង្គ នៅគង់ព្រះជន្មនៅ ឡើយ ទោះជាប្រថាប់នៅឆ្ងាយរាប់ពាន់យោជន៍ ខ្ញុំព្រះករុណាក៏នឹងទៅគាល់អោយទាល់តែបាន កាល បើព្រះពុទ្ធជាម្ចាស់ទ្រង់បរិនិព្វានហើយ ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធជាម្ចាស់ដែលព្រះបរិនិព្វាន ហើយព្រមទាំងព្រះធម៌ និងព្រះសង្ឃសាវ័កជាទីពឹង ។ ខ្ញុំព្រះករុណាសូមវៀរចាកការសំលាប់សត្វ ការលួចឆក់ ការប្រព្រឹត្តកន្លងក្នុងកាម មិននិយាយកុហក និង មិនផឹកទឹកស្រវឹង ។

កាលដែលព្រះរាជកុមារតាំងនៅក្នុងសរណៈនិងសីលហើយ ព្រះថេរៈក៏ទូលថា ម្នាលរាជកុមារ មិនមានប្រយោជន៏ក្នុងការនៅក្នុងព្រៃនេះទេ អ្នកនឹងអស់ព្រះជន្មក្នុងអំឡុងពេល៥ខែទៀត ដូច្នេះ អ្នកគួរទៅកាន់សំណាក់រាជបិតារបស់អ្នក ធ្វើបុណ្យទាំងឡាយមានទានជាដើម គប្បីជាអ្នកមានឋាសួគិជាទីទៅក្នុងពេលអនាគតចុះ ។

បន្ទាប់មក ព្រះថេរៈក៏បានចែកព្រះសារីរិកធាតុរបស់ព្រះសម្មាសម្ពុទ្ធអោយព្រះរាជកុមារ ។

ព្រះរាជកុមារត្រាស់ថា ខ្ញុំព្រះករុណានឹងទៅតាមឱវាទរបស់ព្រះអង្គ សូម្បីព្រះអង្គក៏គប្បីទៅទីនោះ ដើម្បីអនុគ្រោះដល់ខ្ញុំព្រះករុណា ។

ពេលព្រះថេរៈទទួលនិមន្តហើយ ព្រះរាជកុមារក៏ថ្វាយបង្គំលា ហើយទ្រង់យាងត្រឡប់ទៅនគររបស់ព្រះបិតា ក្រាបទូលសព្វរឿងរ៉ាវអោយទ្រង់ជ្រាប ។

ព្រះរាជាទ្រង់ព្រះសណ្តាប់ហើយ មានព្រះរាជបំណងនឹងអភិសេកអោយព្រះរាជកុមារឡើងគ្រងរាជសម្បត្តិ ។

ព្រះរាជកុមារក្រាបទូលថា ទូលព្រះបង្គំមានអាយុតិច បួនខែទៀតក៏នឹងដល់នូវមរណកាល ប្រយោជន៏អ្វីដោយរាជសម្បត្តិ ទូលបង្គំនឹងអាស្រ័យព្រះបិតាធ្វើតែបុណ្យប៉ុណ្ណោះ ។

ក្រោយមកព្រះរាជកុមារបានត្រាស់សរសើរគុណព្រះរតនត្រ័យ និង គុណព្រះមហាកច្ចាយនៈ ។

ព្រះរាជាទ្រង់ព្រះសណ្តាប់ហើយ ទ្រង់ជ្រះថ្លាក្នុងព្រះរតនត្រ័យនិងព្រះថេរៈ ទ្រង់ព្រះមេត្តាប្រោស អោយសាងវិហារធំមួយហើយទ្រង់បញ្ជូនទូតអោយទៅទទួលព្រះមហាកច្ចាយនៈ និមន្តអោយគង់ក្នុង វិហារ ទំនុកបំរុងដោយបច្ច័យ៤ដោយគោរព តាំងនៅក្នុងសរណៈនិងសីល ។

ព្រះរាជកុមារសមាទានសីល ទំនុកបំរុងព្រះថេរៈ និង ភិក្ខុទាំងឡាយដោយសេចក្តីគោរព អោយ ទានស្តាប់ធម៌ វេលាកន្លងទៅរយៈពេលបួនខែក៏អស់ព្រះជន្មទៅកើតក្នុងឋានសួគ៌ជាន់តាវត្តិង្ស ។

*(ចូឡរថវិមានវត្ថុ)*

រឿងរបស់ព្រះរាជកុមារនេះមានខ្លឹមសារគួរត្រិះរិះដូចតទៅ:

១-ជីវិតត្រូវជរានិងព្យាធិនាំទៅកាន់សេចក្តីស្លាប់ដោយមិនអាចទប់ទល់បាន អ្នកដែលឃើញ ភ័យក្នុងសេចក្តីស្លាប់គួរប្រញាប់ធ្វើបុណ្យ មានតែបុណ្យប៉ុណ្ណោះ ដែលជាទីពឹងរបស់អ្នកដែលទៅកាន់ បរលោក របស់ដទៃក្រៅពីបុណ្យមិនអាចយកជាទីពឹងបានទេ ។ ទោះបីជាមានយសសក្តិតំណែងខ្ពង់ ខ្ពស់ មានអំណាចវាសនា មានទ្រព្យសម្បត្តិនិងបរិវារច្រើនប៉ុណ្ណាក៏ដោយ ក៏មិនអាចនាំជាប់ខ្លួនទៅបរលោក បានឡើយ ពេលស្លាប់ទៅត្រូវបោះបង់ចោលអស់ មានតែបុណ្យប៉ុណ្ណោះដែលអាចនាំជាប់ខ្លួន ទៅបរលោក បានអ្នកដែលតក់ស្លុតចំពោះមរណភ័យ គួរតែខំសន្សំបុណ្យអោយហើយចាប់តាំងពីថ្ងៃនេះតទៅ ។

២-តំលៃរបស់មនុស្សនៅត្រង់អំពើល្អ សុជាតិកុមារ ទោះជាអាយុខ្លីតែក៏មានឱកាសបានធ្វើអំ ពើល្អ ដូចជា អោយទាន រក្សាសីល ស្តាប់ធម៌ មិនឥតប្រយោជន៍ដែលគេបានកើតមកជាមនុស្ស ប្រសើរ ជងបុគ្គលប្រភេទ *ធំព្រោះបរិភោគបាយ ចាស់ព្រោះកើតយូរ* ដែលចាស់តែអាយុមិនចាស់ដោយគុណធម៌ បណ្តោយអោយជីវិតកន្លងហួសទៅទទេៗ ដោយមិនបានកសាងអំពើល្អអ្វីបង្ការទុកបន្តិចសោះ។

៣-ព្រះមហាកច្ចាយនៈទទួលស្វាគមន៍យ៉ាងល្អ ទាំងដោយធម៌និងដោយអាមិស ធ្វើឱ្យសុជាតិ កុមារទ្រង់ជ្រះថ្លា។ ខាងផ្លូវលោកក៏ដូចគ្នា ហាងលក់ដូរ រានលក់ដូរណាចេះទទួលស្វាគមន៍រាក់ទាក់បាន ល្អតែងតែមានអតិថិជនចេញចូលមិនដាច់ ហេតុនេះ ការទទួលស្វាគមន៍ទើបជាហេតុម្យ៉ាងនៃសេចក្តី ចំរើនទាំងផ្លូវលោកនិងផ្លូវធម៌ ។

៤-មនុស្សល្អនិងមនុស្សអាក្រក់រមែងត្រេកអរផ្សេងគ្នា មនុស្សល្អរមែងត្រេកអរក្នុងសីលធម៌ ត្រេកអរចំពោះអំពើជាកុសល មិនប្រព្រឹត្តអំពើក្តៅក្រហាយដល់ខ្លួននិងអ្នកដទៃ។ ចំណែកមនុស្សអាក្រក់ត្រេកអរតែនឹងអំពើអាក្រក់អំពើដែលនាំទុក្ខទោសដល់ខ្លួននិងអ្នកដទៃ។

៥-ជីវិតមនុស្សយើងមិនទៀង ក្មេងក៏អាចស្លាប់មុនចាស់ កូនក៏អាចស្លាប់មុនឪពុកម្តាយ ព្រោះ *មនុស្សយើងកាលបើកើតមកហើយក៏ចាស់ល្មមនឹងអាចស្លាប់បានគ្រប់គ្នា* ហេតុនេះ ទើបមិនគួរឈ្លក់វង្វេងស្រវឹងធ្វេសប្រហែសក្នុងជីវិតថា យើងនៅរស់យូរតទៅទៀត យើងមិនងាយស្លាប់ទេ ។ គួរប្រើពេលវេលាដែលនៅសល់អោយមានប្រយោជន៍ កុំបណ្តោយអោយពេលវេលាកន្លងទៅដោយទទេៗ ក្នុងមួយថ្ងៃទោះតិចឬច្រើនក៏គួរអោយបានអ្វីខ្លះក្នុងកងការកុសល ដោយហោចទៅសូម្បីតែរំលឹកដល់គុណព្រះរតនត្រ័យនៅតែក្នុងចិត្តមួយថ្ងៃម្តងក៏ជាការប្រសើរនិងជាបុណ្យកុសលដ៏ខ្ពង់ខ្ពស់ ព្រោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាកែវដ៏វិសេសអាចញ៉ាំងសេចក្តីប្រាថ្នាទាំងពួងអោយសំរេចបាន ។

# ដូចម្តេចឈ្មោះថាស្រលាញ់ខ្លួន?

ព្រះបាទបសេនទិកោសលក្រាបទូលព្រះដ៏មានព្រះភាគថា:

ខ្ញុំព្រះករុណាបានកើតគំនិតមួយឡើងថា បុគ្គលទាំងឡាយណាប្រព្រឹត្តទុច្ចរិតដោយកាយ វាចា ចិត្ត បុគ្គលទាំងឡាយនោះឈ្មោះមិនស្រលាញ់ខ្លួន សូម្បីពួកគេពោលថាគេស្រលាញ់ខ្លួនក៏ ដោយក៏ពួកគេនៅតែមានឈ្មោះថាមិនស្រលាញ់ខ្លួន ព្រោះហេតុថា បុគ្គលអ្នកក្រោធខឹងចំពោះគ្នានឹងគ្នា រមែងធ្វើសេចក្តីវិនាសដល់គូសត្រូវរបស់ខ្លួនដោយប្រការណា ពួកគេក៏រមែងធ្វើសេចក្តីវិនាសអោយដល់ខ្លួនឯងដោយប្រការនោះ ដូច្នេះ ពួកគេឈ្មោះថាមិនស្រលាញ់ខ្លួន ។ ចំណែក បុគ្គលទាំងឡាយណា ប្រព្រឹត្តសុចរិតដោយកាយ វាចា ចិត្ត បុគ្គលទាំងឡាយនោះឈ្មោះថាស្រលាញ់ខ្លួន បើទុកណាជាពួកគេពោលថា មិនស្រលាញ់ខ្លួនក៏ដោយ ព្រោះហេតុថា នរជនដែលស្រលាញ់គ្នានឹងគ្នា រមែងធ្វើសេចក្តីល្អសេចក្តីចំរើនអោយដល់មនុស្សដែលខ្លួនស្រលាញ់ដោយប្រការណា ពួកគេរមែងធ្វើសេចក្តីល្អសេចក្តីចំរើនអោយដល់ខ្លួនដោយប្រការនោះ ដូច្នេះពួកគេ ទើបបានឈ្មោះថាស្រលាញ់ខ្លួន ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់អះអាងថា ពិតជាដូច្នោះមែន ហើយត្រាស់ថាៈ

បើបុគ្គលដឹងថា ខ្លួនជាទីស្រលាញ់ហើយនោះ ក៏មិនគួរប្រព្រឹត្តនូវអំពើបាបទេ ព្រោះថា សេចក្ដីសុខនោះជាផលដែលបុគ្គលអាក្រក់មិនទទួលបានដោយងាយទេ។

កាលសេចក្ដីស្លាប់ចូលមកដល់ខ្លួនហើយបុគ្គលរមែងលះទាំងភពមនុស្សទៅ ក៏អ្វីជាសម្បត្តិរបស់គេ? ហើយគេនឹងនាំអ្វីទៅបាន? ម្យ៉ាងទៀតតើអ្វីទៅនឹងជាប់តាមគេទៅប្រៀបដូចស្រមោលអន្ទោលតាមប្រាណ ដូច្នោះ ។

បុគ្គលដែលកើតមកហើយចាំបាច់ត្រូវតែស្លាប់ បានធ្វើកម្មគឺបុណ្យនិងបាបណាមួយទុកក្នុងលោកនេះ បុណ្យនិងបាបនោះឯងជាសម្បត្តិរបស់គេ ហើយគេនឹងនាំយកបុណ្យ និង បាបនោះទៅជាមួយផង ម្យ៉ាងទៀតបុណ្យនិងបាបនោះរមែងជារបស់ជាប់តាមខ្លួនគេ ប្រៀបដូចស្រមោលអន្ទោលតាមប្រាណ ដូច្នោះ។ ហេតុនោះ បុគ្គលគប្បីធ្វើអំពើល្អសន្សំ ទុកជាសម្បត្តិក្នុងបរលោក ព្រោះបុណ្យទាំងឡាយ រមែងជាទីពឹងរបស់សត្វទាំងឡាយ ក្នុងបរលោក ។ *(បិយសូត្រ)*

ព្រះបាទបសេនទិកោសលក្រាបទូលព្រះដ៏មានព្រះភាគជាម្ចាស់ថាៈ

ខ្ញុំព្រះអង្គបានត្រិះរិះឃើញថា បុគ្គលទាំងឡាយណាប្រព្រឹត្តទុច្ចរិតដោយកាយ វាចា ចិត្ត បុគ្គលទាំងឡាយនោះឈ្មោះថាជាអ្នកមិនរក្សាខ្លួន បើទុកណាជាពលដំរី ពលសេះ ពលរទេះ និង ពលថ្មើរជើងថែរក្សាពួកគេក៏ដោយ ក៏ឈ្មោះថាពួកគេជាអ្នកមិនរក្សាខ្លួន ព្រោះថា ការរក្សា ដូច្នេះជាការរក្សាខាងក្រៅ មិនមែនជាការរក្សាខាងក្នុង ចំណែកបុគ្គលទាំងឡាយណាប្រព្រឹត្ត សុចរិតដោយកាយ វាចា ចិត្ត បុគ្គលទាំងឡាយនោះ ឈ្មោះថាជាអ្នករក្សាខ្លួន ទោះជាពលដំរី ពល សេះ ពលរទេះ ពលថ្មើរជើងមិនរក្សាពួកគេក៏ដោយក៏ពួកគេឈ្មោះថាជាអ្នករក្សាខ្លួន ព្រោះថា ការរក្សាដូច្នេះជាការរក្សាខាងក្នុង មិនមែនជាការរក្សាខាងក្រៅទេ ហេតុនោះពួកគេទើបឈ្មោះថាជាអ្នករក្សាខ្លួន ។

ព្រះសម្មាសម្ពុទ្ធទ្រង់អះអាងថាពិតដូច្នោះមែន ។ *(អត្តរក្ខិតសូត្រ)*

ព្រះរាជតម្រិះរបស់ព្រះបាទបសេនទិកោសលនេះជាការពិតដែលមិនអាចនរណាប្រកែកបាន ពតិមាននៅក្នុងទំព័រកាសែតជាគ្រឿងបញ្ជាក់យ៉ាងច្បាស់ បណ្ដាពួកអ្នកមានឥទ្ធិពលឬបងធំដែលប្រព្រឹត្តអាក្រក់ទាំងឡាយ ទោះបីជាមានឥទ្ធិពល មានការប្រយ័ត្នប្រយែងរក្សាខ្លួន មានខ្មាន់កាំភ្លើងចាំការពារយ៉ាងរឹងមាំយ៉ាងណាក៏ដោយ ក៏នៅតែជួបប្រទះវិបត្តិរហូតដល់អស់ជីវិតរាប់មិនអស់ ព្រោះការការពាររក្សា

ទាំងអស់នេះ គ្រាន់តែជាការការពារខាងក្រៅប៉ុណ្ណោះ ទោះបីជាខំរក្សាការពារយ៉ាងណា ក៏មិនរួចផុតពីកម្មអាក្រក់ដែលខ្លួនបានធ្វើនោះដែរ ចំណែកអ្នកដែលមានជីវិតរស់នៅក៏នៅទាំងភ័យខ្លាច គ្មានសេចក្តីសុខនឹងទៅណាមកណាដោយឥតស្សេរះដូចអ្នកស្រុកទូទៅក៏មិនបាន ទោះបីជានៅក្នុងផ្ទះឬក្នុងឡានក៏គ្មានសុវត្ថិភាព មានឱកាសអាចត្រូវគេលួចបាញ់ ឬត្រូវគេដាក់គ្រាប់បែកបានជានិច្ច ហេតុនេះ អ្នកស្រលាញ់ខ្លួនគួររក្សាខ្លួនអោយល្អដោយការលះបាបបំពេញបុណ្យកុសលអោយបានច្រើន វៀរចាកនូវអកុសលកម្មទាំងបីយ៉ាង គឺ ប្រព្រឹត្តអាក្រក់ និយាយអាក្រក់ និង គំនិតមិនល្អ ទើបបានឈ្មោះថាជាអ្នកស្រលាញ់ខ្លួនដោយពិត ។

ស្រលាញ់ខ្លួន សួនទង្វើ សួនគំនិត
ស្តីត្រូវគិត កុំប្រឌិត អោយមួហ្មង
ស្រលាញ់ខ្លួន កុំរបឹង រឹងប៉ុនប៉ង
ធ្វើកន្លង ចាកក្តីគាប់ ជាប់បាបកម្ម ។
ស្រលាញ់ខ្លួន គួរអប់រំ បន្ទំចិត្ត
កុំគួចគិត ចិត្តបៀតបៀន អោយរញ៉ុំ
ចៀសអោយផុត ដុតអោយអស់ ចិត្តប្រេះស្រាំ
ខំចងចាំ ចិត្តមេត្តា ត្រាប្រណី ។
ស្រលាញ់ខ្លួន ខំធ្វើល្អ បវរគាប់
ចេះគំនាប់ ជាប់តំណ លើលោកិយ
ចេះសាងមិត្ត ចិត្តស្មោះសរ ត្រង់ប្រពៃ
ជនអប្រិយ លៃចរចៀស វេះអោយឆ្ងាយ ។